រោងចក្រកាន់តែប្រសើរនៅកម្ពុជា

# ការអនុវត្តន៍ល្អ

## សំភារៈការពារខ្លួន (PPE)

រោងចក្រចាំបាច់ត្រូវផ្តល់សំភារៈការពារខ្លួន (PPE) ដល់កម្មករ ។ ប្រភេទសំភារៈការពារខ្លួន អាចមានច្រើនប្រភេទអាស្រ័យទៅតាមលក្ខណៈការងារដែលត្រូវធ្វើ ។

### *ការអនុវត្តន៍ល្អសំរាប់ការផ្តល់អោយ និងការប្រើប្រាស់ PPE*

ផ្តល់ស្រោមដៃដែក ទៅអោយកម្មករ ដែលប្រើឧបករណ៏កាត់ក្រណាត់ ដើម្បីការពារពួកគេ មិនអោយរងរបួសម្រាមដៃ (រូបភាពទី១)

ផ្តល់ម៉ាស់ការពារធូលីអោយទៅកម្មករ (ឧ. អ្នកដេរ) ដើម្បីការពារពួកគេមិនអោយដកដង្ហើមស្រូបយកធូលីនៃសារធាតុគីមី (រូបភាពទី២)

ផ្តល់ម៉ាស់ដែលត្រឹមត្រូវទៅអោយកម្មករដែលប្រើ ឬប៉ះពាល់ជាមួយនឹងសារធាតុគីមី (រូបភាពទី៣)

សំភារៈការពារខ្លួន ដែលចាស់ ឬរហែកមិនផ្តល់ការការពារដល់កម្មករទេ ។ ត្រូវធានាថា សំភារៈការពារខ្លួនស្ថិតក្នុងល័ក្ខខ័ណ្ឌល្អប្រសើរ ហើយតែងតែផ្លាស់ប្តូរវាបន្ទាប់ពីរយៈពេលប្រើប្រាស់ដែលកំណត់ដោយអ្នកផលិតត្រូវបានផុតកំណត់ ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ កាត់បន្ថយហានិយភ័យនៃគ្រោះថ្នាក់ និងជំងឺ
- ✓ កាត់បន្ថយចំណាយលើការព្យាបាលនាពេលអនាគត
- ✓ ធ្វើអោយបរិយាកាសការងារកាន់តែមានសុវត្ថិភាព

### តាមរបៀបណា:

- ✓ ទិញសំភារៈការពារខ្លួន ដែលងាយរកបាន តែមិនមែនមានតំលៃថោកបំផុតនោះទេ ។ សំភារៈដែលមានគុណភាពល្អធន់បានយូរ និងផ្តល់ការការពារខ្ពស់
- ✓ ផ្តល់ការបណ្តុះបណ្តាល ដើម្បីបង្ហាញពីរបៀបប្រើប្រាស់ សំភារៈការពារខ្លួនអោយបានត្រឹមត្រូវ
- ✓ ផ្តល់ការបណ្តុះបណ្តាលជាប្រចាំ ដើម្បីអប់រំកម្មករពីហានិភ័យនៅកន្លែងធ្វើការ និងពីអត្ថប្រយោជន៏នៃការប្រើប្រាស់សំភារៈការពារខ្លួននៅក្នុងកន្លែងធ្វើការ
- ✓ ធានាថាកម្មករពាក់សំភារៈការពារខ្លួនត្រឹមត្រូវនៅរាល់ពេលចាំបាច់

### តំលៃ:

$

$ តំលៃទាប

$$ តំលៃមធ្យម

$$$ តំលៃខ្ពស់

អង្គការពលកម្មអន្តរជាតិ

ប្រសិនបើលោកអ្នកមានសំនួរ សូមទាក់ទងមកអង្គការពលកម្មអន្តរជាតិតាមរយៈអ៊ីម៉ែល betterfactories@ilo.org